**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១២៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៥អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ និងសារាចរណែនាំការអនុវត្តន៍ព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈលេខ ០០៥ សហវ.ទរ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និងសាធារណការ
- យោងតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សំរេច

**មាត្រា ១ .-**

មាត្រា ៦ នៃអនុក្រឹត្យលេខ ១៥អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និងសាធារណការ ត្រូវបានកែប្រែដូចតទៅ ÷

មាត្រា ៦ថ្មី : ម.ព.ស.ស ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| -តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -តំណាង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| -តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និសំណង់ | សមាជិក |
| -អគ្គនាយក ម.ព.ស.ស. | សមាជិក |
| -តំណាង និយោជិត ម.ព.ស.ស. | សមាជិក |

សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬ អាជ្ញាធរ-ដែលខ្លួនតំណាងអោយ ។ តំណាងនិយោជិតត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមនិយោជិត នៃមន្ទីរពិសោធន៍សំណង់ និងសាធារណការ ។

**មាត្រា ២.-**

ក្រៅពីនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និងសាធារណការ នៅរក្សាទុកជាធរមានដដែល ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ